**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គិសនីកម្ពុជា**

លេខ : ២០១៣អសក.អក.អច

# សេចក្ដីជូនដំណឹង

**អគ្គិសនីកម្ពុជា**មានកិត្តិយស សូមទូលថ្វាយ និងជម្រាបជូន សម្ដេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ដែលជាអតិថិជនរបស់អគ្គិសនីកម្ពុជាជ្រាបថា : ដើម្បីអនុវត្តការងារជួសជុល ថែទាំ និងផ្លាស់ប្ដូរបរិក្ខារប្រព័ន្ធបណ្ដាញចែកចាយ អគ្គិសនីកម្ពុជានឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី នៅតំបន់ភ្លើងមួយចំនួនទៅតាមពេលវេលា និងទីកន្លែងដោយមូលហេតុដូចខាងក្រោម :

១. ថ្ងៃព្រហស្បតិ៍ទី០៦ ខែមីនា ឆ្នាំ២០១៤ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនីចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង ១២ម៉០០ (១)នៅតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិគៀនឃ្លាំង ភូមិ៣ ក្នុងសង្កាត់ជ្រោយចង្វារ ខណ្ឌឬស្សីកែវ (២)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិឫស្សី ក្នុងសង្កាត់ស្ទឹងមានជ័យ ភូមិចំរើនផល ភូមិសន្សំកុសល២ ក្នុងសង្កាត់បឹងទំពុន ខណ្ឌមានជ័យ និង (៣)ចាប់ពីម៉ោង១២ម៉០០ ដល់ម៉ោង១៤ម៉០០ នៅតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្ដោយផ្លូវកែវចិន្ដា ក្នុងសង្កាត់ជ្រោយចង្វារ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដើម្បីរៀបចំកែលម្អខ្សែបណ្ដាញផ្គត់ផ្គង់អគ្គិសនី ។

២. ថ្ងៃសុក្រទី០៧ ខែមីនា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១២ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្ដោយផ្លូវលេខ១៧៦៩ ក្នុងសង្កាត់ក្រាំងធ្នង់ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដើម្បីរៀបចំកែលម្អខ្សែបណ្ដាញផ្គត់ផ្គង់អគ្គិសនី ។

៣. ថ្ងៃសៅរ៍ទី០៨ ខែមីនា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១២ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្ដោយផ្លូវជាតិលេខ6A ចាប់ពីគល់ស្ពានជ្រោយចង្វារ រហូតដល់ភូមិគៀនឃ្លាំង ក្នុងសង្កាត់ជ្រោយចង្វារ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដើម្បីតម្លើងបរិក្ខារបណ្ដាញផ្គត់ផ្គង់អគ្គិសនី ។

៤. ថ្ងៃសៅរ៍ទី០៨ និងថ្ងៃអាទិត្យទី០៩ ខែមីនា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៨ម៉០០ ដល់ម៉ោង១៧ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនីនៅ (១)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិឫស្សី ភូមិដំណាក់ធំ ក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ (២)តំបន់ភ្លើងលេខ ប.ត256, P125, P378, P512 ស្ថិតនៅតាមបណ្ដោយផ្លូវវេងស្រេង ក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ និង (៣)តំបន់ភ្លើងលេខ P171 ស្ថិតនៅភូមិទ្រា៣ ក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដើម្បីរុះរើគន្លងខ្សែបណ្ដាញបង្កលក្ខណៈដល់ការដ្ឋានពង្រីកផ្លូវវេងស្រេង ។

អាស្រ័យហេតុនេះ សូមសម្ដេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ជ្រាបជាព័ត៌មាន និងសូមអធ្យាស្រ័យចំពោះការដាច់ចរន្តអគ្គិសនីនេះ ដោយអនុគ្រោះ ។

រាជធានីភ្នំពេញ . ថ្ងៃទី....០៣....ខែ....មីនា.....ឆ្នាំ២០១៤

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

ELECTRICITE DU CAMBODGE

**កែវ_រតនៈ**